សុន្ទរកថារបស់**ឯកឧត្តម គូម៉ាម៉ារូ យូជិ** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់
ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ
សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ របស់ប្រទេសជប៉ុន

២៤ មិនា ២០១៤

**សូមគោរព ឯកឧត្តម ពេជ្រ វាសនា នាយកមជ្ឈមណ្ឌលសេវាបច្ចេកទេសធនធានទឹក និងឧតុនិយម!**
**សូមគោរព លោក ឡុង ផលគុណ ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្តបាត់ដំបង!**
**សូមគោរព លោក នួន គ្រឹះស្នា ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្តសៀមរាប!**
**សូមគោរព លោក ផេង គា នាយកប្រតិបត្តិអង្គការទឹកភ្លៀងកម្ពុជា!**
**សូមគោរព អស់លោក លោកស្រី!**

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយដើម្បីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយចំនួន៣សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិដែលរួមមាន គម្រោងស្តារប្រឡាយមុខបួនក្នុងខេត្តបាត់ដំបង គម្រោងស្តារប្រឡាយលេខ៧ក្នុងខេត្តសៀមរាប និងគម្រោងកែលម្អបរិក្ខារអនាម័យក្នុងសាលាបឋមសិក្សាចំនួន៦នៅក្នុងស្រុកកងមាស និងស្រុកបាធាយ ខេត្តកំពង់ចាម។

គម្រោងដែលយើងបានចុះហត្ថលេខានៅថ្ងៃនេះមានគោលដៅអភិវឌ្ឍវិស័យកសិកម្ម និងអនាម័យ។ យើងទទួលស្គាល់ថាវិស័យទាំង២នេះគឺជាវិស័យអាទិភាពសម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជា។ ដូចដែលយើងទាំងអស់គ្នាបានដឹងហើយថា វិស័យកសិកម្ម គឺជា វិស័យធំជាងគេក្នុងប្រទេសដែលស្រូបយកកំលាំងពលកម្មជាង ៦០% ហើយយើងជឿជាក់ថា ការអភិវឌ្ឍន៍វិស័យនេះគឺជាគន្លឹះដ៏សំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ ក៏ដូចជាការបង្កើនប្រាក់ចំណូលនៅតាមតំបន់ជនបទផងដែរ។ វិស័យសុខាភិបាល និងអនាម័យមានសារៈសំខាន់ណាស់សម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជាប្រកបដោយចីរភាព ជាពិសេស ការកែលម្អអនាម័យតាមសាលារៀនគឺជាការវិនិយោគដ៏ត្រឹមត្រូវបំផុតសម្រាប់ក្មេងៗជំនាន់ក្រោយ។

គម្រោងទីមួយមានថវិកាសរុប ១១៤,២៦៨ ដុល្លាអាមេរិក គឺដើម្បីពង្រីកផ្ទៃដីស្រោចស្រព ក្នុងស្រុកថ្មគោល ខេត្តបាត់ដំបង។ គម្រោងនេះរួមមានការស្តារប្រឡាយរងប្រវែង៨៥០ម៉ែត្រ សាងសង់ប្រឡាយទីបីប្រវែង១,០៥០ម៉ែត្រ និងសំណង់បញ្ចូលទឹក៣កន្លែង។ យើងសង្ឃឹមថាប្រជាជនប្រមាណ៨០គ្រួសារក្នុងតំបន់នឹងទទួលបានទឹកស្រោចស្រពដីស្រែយ៉ាងជាប់លាប់។

គម្រោងទីពីរមានថវិកាសរុប១២១,៥៧៨ដុល្លាអាមេរិក គឺដើម្បីពង្រីកផ្ទៃដីស្រោចស្រពក្នុងស្រុកពួក ខេត្តសៀមរាប។ គម្រោងនេះរួមមាន ការស្តារប្រឡាយរងប្រវែង៣,៧០០ម៉ែត្រ និងសាងសង់ជញ្ជាំងការពារ ស្ពានបេតុង និងលូចំនួន១០កន្លែង។ យើងសង្ឃឹមថាប្រជាជនប្រមាណ១,៦០០គ្រួសារក្នុងតំបន់នឹងទទួលបានទឹកស្រោចស្រពដីស្រែជាប្រចាំ។

គម្រោងទីបីមានថវិកាសរុប ២៨,៦៥៦ដុល្លាអាមេរិក គឺដើម្បីកែលម្អបរិក្ខារអនាម័យក្នុងសាលាបឋមសិក្សាចំនួន៦នៃស្រុកកងមាសនិងស្រុកបាធាយ ខេត្តកំពង់ចាម។ គម្រោងនេះរួមមានការសាងសង់អាងស្តុកទឹកភ្លៀងចំនួន៦ កន្លែងលាងដៃចំនួន៥ កន្លែងផឹកទឹកចំនួន៦ និងបន្ទប់ទឹក១០ ព្រមទាំងជួសជុលបន្ទប់ទឹក១១ផ្សេងទៀត។ យើងសង្ឃឹមថាសិស្សានុសិស្ស និងលោកគ្រូ-អ្នកគ្រូប្រមាណ២,៤០០នឹងទទួលបានអត្ថប្រយោជន៍ពីគម្រោងនេះ តាមរយៈការកែលម្អបរិក្ខារអនាម័យទាំងនេះ។

រដ្ឋាភិបាលជប៉ុនបាន និងកំពុងបន្តផ្តល់ការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាតាមរយៈការគាំទ្រដល់គម្រោងអភិវឌ្ឍជាច្រើន។ គម្រោងក្នុងវិស័យកសិកម្ម និងសុខាភិបាលរួមមានការស្តារប្រព័ន្ធធារាសាស្ត្រ ការផ្ទេរបច្ចេកទេសកសិកម្ម ការកែលម្អមន្ទីរពេទ្យ និងគ្លីនិកនានា ព្រមទាំងការអភិវឌ្ឍធនធានមនុស្សសម្រាប់ផ្នែកសុខាភិបាលជាដើម។ គម្រោងទាំងបីនេះធ្វើឡើងតាមគោលការណ៍នៃយុទ្ធសាស្ត្រផ្តល់ជំនួយរបស់ជប៉ុនសម្រាប់កម្ពុជា និងស្របតាមទស្សនៈនៃការផ្តល់ជំនួយដើម្បីលើកស្ទួយសន្តិសុខមនុស្សជាតិសម្រាប់ប្រជាជនងាយរងគ្រោះផងដែរ។

ខ្ញុំសង្ឃឹមថា គម្រោងទាំងបីនេះនឹងត្រូវបានអនុវត្តយ៉ាងរលូន និងប្រកបដោយប្រសិទ្ធភាព ព្រមទាំងថែទាំយ៉ាងត្រឹមត្រូវដើម្បីប្រជាជនកាន់តែច្រើនអាចទទួលបានអត្ថប្រយោជន៍ពីគម្រោងទាំងនេះ។

ជាចុងក្រោយនេះខ្ញុំសង្ឃឹមយ៉ាងមុតមាំថាគម្រោងនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!